# របាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ ២០២៣

០១ មករា - ៣១ មីនា ២០២៣

## អ អិម អេ (ខេមបូឌា) ម.ក

R M A (CAMBODIA) PLC.



ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក
ទីស្នាក់ការចុះបញ្ជីផ្ទះលេខ ២៧ ផ្លូវលេខ១៣៤ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទទំនាក់ទំនង: +៨៥៥ (0) ២៣-៨៨៨-000, ទូរស័ព្ទចល័ត: +៨៥៥ (0) ២៣-៤២៦-៧៥២
www.cambodia.rmagroup.net

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាពាន់រៀល) | ត្រីមាសទី១ ២០២៣ | ២០២២ | ២០២១ |
| --- | --- | --- | --- |
| ទ្រព្យសកម្មសរុប | ៩៥៨.៦៦៨.៤១៨ | ៨៨៩.២៩៥.២៣២ | ៦០៨.១៥៩.៥៣០ |
| បំណុលសរុប | ៤៧១.០៩៥.៦៤២ | ៤៥១.៣៩២.៤៣៣ | ៣២២.២៤០.៨២០ |
| មូលធនក្រុមហ៊ុនសរុប | ៤៨៧.៥៧២.៧៧៦ | ៤៣៧.៩០២.៧៩៩ | ២៨៥.៩១៨.៧១០ |

| ប្រាក់ចំណេញ/(ខាត) (គិតជាពាន់រៀល) | ត្រីមាសទី ១ ២០២៣ | ត្រីមាសទី ១ ២០២២ | ត្រីមាសទី ១ ២០២១ |
| --- | --- | --- | --- |
| ចំណូលសរុប | ៦៣១.១៨៨.៣០៦ | ៤២៩.៦៦៨.៩១៧ | ៤៨១.៦៥៥.០០៨ |
| ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ | ៨៨.៧១៣.៥០៩ | ៥៤.៣៨២.៧៤៣ | ៥៩.៤៣៥.៨៤៧ |
| ប្រាក់ចំណេញ (ខាត) ក្រោយបង់ពន្ធ | ៦៩.៦៥៥.៩២៣ | ៤៨.០៧១.៣៧២ | ៤៩.២៨៧.៩៧៤ |
| លទ្ធផលចំណេញលម្អិតក្នុងគ្រា | ៦២.៥៣៧.៨០៧ | ៤៦.២៣៣.២១១ | ៤៩.១៤៤.៥៧៥ |

| អនុបាតហិរញ្ញវត្ថុ | ត្រីមាសទី ១ ២០២៣ | ២០២២ | ២០២១ |
| --- | --- | --- | --- |
| អនុបាតសាធនភាព | ១,០ | ១,០ | ១,១ |
| អនុបាតចរន្ត (Current Ratio) | ១,៩ | ២,០ | ២,០ |
| អនុបាតចរន្តលឿន (Quick Ratio) | ០,៥ | ០,៧ | ១,០ |

| អនុបាតចំណេញភាព | ត្រីមាសទី ១ ២០២៣ | ត្រីមាសទី ១ ២០២២ | ត្រីមាសទី ១ ២០២១ |
|---|---|---|---|
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម | ៦,៨% | ៨,២% | ១១,៦% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម | ១៣,៥% | ១៥,០% | ២៣,៤% |
| គម្លាតចំណេញដុល (Gross Profit Margin) | ១៨,៣% | ១៧,៦% | ១៥,៣% |
| គម្លាតចំណេញ (Profit Margin) | ៩,៩% | ១០,៨% | ១០,២% |
| អនុបាតលទ្ធភាពបង់ការប្រាក់ | ១៧,៣ | ២៨,២ | ២៦,១ |

## ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប










ប្រាក់ចំណូល និង ចំណូលសុទ្ធ (គិតជាពាន់រៀល)
2,500,000,000
2,000,000,000
1,500,000,000
1,000,000,000
500,000,000
-
12%
11%
10%
9%
8%
7%
6%
២.២០៣.២៥៣.៤៥៣
១.៦២៦.៥៤០.០២៤
៦៣១.១៨៨.៣០៦
១០%
១១%
១០%
២០២១
២០២២
ត្រីមាសទី១ ឆ្នាំ២០២៣
ប្រាក់ចំណូល
ចំណូលសុទ្ធ %

## សមាជិកក្រុមប្រឹក្សាភិបាល



លោក Chris Manley | លោក ងន សាំង | លោក Kevin Whitcraft | លោក Tom Whitcraft | លោក Ith Vichit

លោក Kevin Whitcraft

ប្រធានក្រុមប្រឹក្សាភិបាល

លោក ងន សាំង

អភិបាលប្រតិបត្តិ

លោក Tom Whitcraft

អភិបាលមិនប្រតិបត្តិ

លោក Chris Manley

អភិបាលមិនប្រតិបត្តិ

លោក Ith Vichit

អភិបាលឯករាជ្យ

## សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

វិនិយោគិនជាទីគោរព

ក្នុងរបាយការណ៍ប្រចាំត្រីមាសមុនៗ ខ្ញុំបាទបានជម្រាបជូនអំពីរបាយការណ៍សង្ខេបស្តីពីលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុរបស់ ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក (តទៅនេះហៅកាត់ថា "ក្រុមហ៊ុន RMAC") ស្របទៅតាមលក្ខខណ្ឌតម្រូវរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក)។

ថ្មីៗនេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានអះអាងថា សេដ្ឋកិច្ចកម្ពុជានឹងសម្រេចបានកំណើនយ៉ាងរឹងមាំ ៥.៥% នៃផលិតផលក្នុងស្រុកសរុបរបស់ខ្លួននៅឆ្នាំ ២០២៣។ ទោះជាយ៉ាងណាក៏ដោយ ស្ថានភាពសេដ្ឋកិច្ចពិភពលោកដែលកំពុងចុះខ្សោយ គួបផ្សំនឹងសង្គ្រាមអ៊ុយក្រែន និងរុស្ស៊ី និងការឡើងថ្លៃអត្រាការប្រាក់បានធ្វើឱ្យកំណើនសេដ្ឋកិច្ចនៅកម្ពុជាក្នុងត្រីមាសទី១ ឆ្នាំ២០២៣ មានភាពទន់ខ្សោយ។ អតិថិជនមានការលំបាកក្នុងការទទួលបានប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុដែលបានបន្ថយល្បឿននៃការងើបឡើងវិញក្រោយ កូវីដ-១៩ នៅក្នុងវិស័យឧស្សាហកម្មផ្សេងៗ។ ម្យ៉ាងវិញទៀត វិស័យទេសចរណ៍បាន មានការស្ទុះងើបឡើងវិញ ទោះបីជាមិនសំខាន់ដូចការរំពឹងទុកក៏ដោយ។ អាជីវកម្មអចលនវត្ថុបានជាប់គាំងជាមួយនឹងប្រតិបត្តិការយ៉ាងតិចតួចបំផុតដែលត្រូវបានចរចាក្នុងអំឡុងត្រីមាស។ ទីផ្សាររថយន្តទាំងមូលបានធ្លាក់ចុះ -៩% ក្នុងកំឡុងត្រីមាសធៀបនឹងឆ្នាំមុន ទោះបីជាទីផ្សាររថយន្តថ្មីបានកើនឡើង +១២% ក៏ដោយ។

ក្នុងកំឡុងត្រីមាសទី១ នៃឆ្នាំ ២០២៣ RMAC បានផ្តល់នូវការលក់ដ៏រឹងមាំដែលមានការកើនឡើងជាង +៤៦% បើប្រៀបធៀបទៅនឹងត្រីមាសដូចគ្នានៃឆ្នាំ ២០២២។ ប្រាក់ចំណេញសុទ្ធប្រចាំត្រីមាសគឺបានកើនឡើង +៤៥% ។

ក្នុងអំឡុងពេលនេះដែរ ម៉ាករថយន្តចិនថ្មី Changan របស់យើងមានសកម្មភាពយ៉ាងខ្លាំងជាមួយនឹងការចេញលក់ម៉ូដែលថ្មីចំនួន ៤ គឺ UNI-T, UNI-K, CS35 Plus និង CS55 Plus ។ ខាងផ្នែកលក់រថយន្ត Ford ក៏បានរៀបចំពិធីជប់លៀងជាលក្ខណៈពិសេស ដើម្បីថ្លែងអំណរគុណចំពោះទំនុកចិត្ត និងភាពស្មោះត្រង់របស់អតិថិជន។ យើងមានមោទនៈភាពក្នុងការសម្រេចបាននូវព្រឹត្តិការណ៍ថ្មីមួយ ដែលទទួលបានសិទ្ធិជួសជុលថែទាំ រថយន្ត Mercedes-Benz នៅកម្ពុជា ដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមីនា ឆ្នាំ ២០២៣ ។

ក្រុមហ៊ុន RMAC នឹងបន្តអនុវត្តយុទ្ធសាស្រ្តអាជីវកម្មជាក្រុមហ៊ុនផ្គត់ផ្គង់និងថែទាំឈានមុខគេផ្នែកយានយន្ត គ្រឿងបរិក្ខារកសិកម្ម សំណង់ និងគ្រឿងបរិក្ខារជំនួយ (materials handling equipment) ដែលមានស្តង់ដារលំដាប់ពិភពលោកនៅប្រទេសកម្ពុជា។ ក្នុងអំឡុងត្រីមាសនេះ ក្រុមហ៊ុន RMAC បានបន្តបំពេញនូវគោលដៅរយៈពេលវែងរបស់ខ្លួនក្នុងការបំពេញតម្រូវការអតិថិជនកម្ពុជាយើងតាមរយៈការដាក់សម្ពោធនូវផលិតផលថ្មីៗ គួរឱ្យចាប់អារម្មណ៍ដោយផ្តោតលើបច្ចេកវិទ្យាកាត់បន្ថយការប្រើប្រាស់ប្រេងឥន្ធនៈ និងផ្តោតសំខាន់លើសុវត្ថិភាព។ សម្រាប់ផ្នែកទទួលខុសត្រូវសង្គមអ្នកគ្រប់គ្រង RMAC មានមោទនភាពដែលបានបរិច្ចាគធុងសំរាមក្នុងខេត្តព្រះសីហនុ និងបានឧបត្ថម្ភដល់វិទ្យាស្ថានល្បីៗក្នុងប្រទេសកម្ពុជា ដើម្បីរួមចំណែកដល់ចំណេះដឹងបច្ចេកទេសរបស់និស្សិត។ RMAC មានទំនួលខុសត្រូវក្នុងការរៀបចំ

ព្រឹត្តិការណ៍ទទួលខុសត្រូវសង្គម សំខាន់ៗដល់សិស្សានុសិស្សដែលជួបការលំបាកនៅសាលាស្អែកថ្មីកម្ពុជា និងទៅដល់វិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី ជាផ្នែកនៃដំណើរទស្សនកិច្ចប្រកបដោយភាពរួសរាយរាក់ទាក់ និងកក់ក្ដៅ ហើយបុគ្គលិក RMAC របស់យើងបានក៏បានបរិច្ចាគកង់ និងសម្ភារៈសិក្សាផងដែរ។

ខ្ញុំបាទតំណាងឲ្យក្រុមប្រឹក្សាភិបាល សូមថ្លែងអំណរគុណចំពោះអតិថិជនដែលមានភក្ដីភាពដែលបានគាំទ្រដល់ក្រុមហ៊ុនយើងក្នុងគ្រាលំបាកក្នុងព្រះរាជាណាចក្រកម្ពុជាកន្លងមក ហើយយើងក៏សូមជូនពរឲ្យប្រជាជនកម្ពុជាទាំងអស់មានសុវត្ថិភាព និងសុខភាពល្អគ្រប់ៗគ្នា។

លោក Kevin Whitcraft
ប្រធានក្រុមប្រឹក្សាភិបាល

## មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ....................3

ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប ....................5

សមាជិកក្រុមប្រឹក្សាភិបាល ....................7

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ....................8

ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ ....................11

ក .ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ ....................11

ខ .សកម្មភាពអាជីវកម្ម ....................11

គ .ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស ....................12

ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ....................14

ក .លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក ....................14

ខ .រចនាសម្ព័ន្ធប្រាក់ចំណូល ....................14

ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ ....................15

ផ្នែកទី៤ .ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង ....................16

ក .ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ....................16

ខ .កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ ....................16

គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល ....................17

ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ ....................17

ង. ផលប៉ះពាល់នៃអតិផរណា ....................17

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ....................18

ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ ....................18

ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ....................19

## ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

### ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ

| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាខ្មែរ | អ អិម អេ (ខេមបូឌា) ម.ក |
|---|---|
| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាឡាតាំង | RMA (CAMBODIA) PLC |
| លេខកូដស្តង់ដារ | KH2000121A44 |
| អាសយដ្ឋាន | ផ្ទះលេខ ២៧ E1 ផ្លូវ ១៣៤ សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (0) ២៣ ៨៨៣ ៩៨៨ / ១២ ៨៦៧ ៦៩៧ |
| លេខទូរសារ | +៨៥៥ (0) ២៣ ៩២៦ ៧៥២ |
| គេហទំព័រ | www.cambodia.rmagroup.net |
| អ៊ីម៉ែល | saing.ngorn@rmagroup.net |
| លេខចុះបញ្ជីក្រុមហ៊ុន | ០០០០១១២១ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០២ |
| លេខចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ០៦៨/២០ គ.ម.ក សសរ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២០ |
| ឈ្មោះអ្នកតំណាងរបស់ក្រុមហ៊ុនបោះផ្សាយ | លោក ងន សាំង |
| លេខាធិការក្រុមហ៊ុន | លោក មាស សុវណ្ណ (អ៊ីមែល៖ sovan.meas@rmagroup.net) |

### ខ. សកម្មភាពអាជីវកម្ម

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនចែកចាយរថយន្ត កសិកម្ម និងគ្រឿងបន្លាស់ធន់ធ្ងន់នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាក្រុមហ៊ុនផ្តល់ការធានា និងសេវាកម្មក្រោយការលក់សម្រាប់ម៉ាកល្បីៗលំដាប់ពិភពលោករួមមានដូចជា Ford, Jaguar Land Rover, Changan, After-Sales of Mercedes-Benz, John Deere, TCM, JCB, FUSO, Changan និង Piaggio។

ប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះជាក្រុមហ៊ុនផ្តល់សេវាកម្មនាំចូលរថយន្ត និង ផ្តល់ដំណោះស្រាយលើសេវាកម្មផ្សេងៗដែលទាក់ទងនឹងគ្រឿងផ្គត់ផ្គង់ និងសេវាថែទាំក្រោយការលក់។

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនមេរបស់ RMA Group ដែលមានទីស្នាក់ការកណ្តាលប្រតិបត្តិប្រចាំតំបន់នៅទីក្រុងបាងកក ប្រទេសថៃ។

## គ. ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស

ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសត្រូវបានកំណត់ដូចខាងក្រោមៈ

### ការសម្ពោធផលិតផល

**សម្ពោធជាផ្លូវការ** Changan UNI-K

RMA Cambodia សម្ពោធការមកដល់នៃ Changan UNI-K Series 2023 ថ្មីនៅ The Premier Sen Sok ។ ព្រឹត្តិការណ៍នេះបានស្វាគមន៍ភ្ញៀវចំនួន១,៥០០នាក់។




**សម្ពោធជាផ្លូវការ** CHANGAN CS55+ S'23

**RMA Cambodia** បានសម្ពោធការមកដល់ជាផ្លូវការនៃ New Changan CS55 PLUS Series 2023 នៅ The Premier Sen Sok ដែលមានភ្ញៀវចូលរួមសរុប ១៥២០ នាក់។ ពិធីសម្ពោធនេះ ធ្វើឡើងក្រោមវត្តមានដ៏មានកិត្តិយសរបស់ ឯកឧត្តម ចេន សេងហៀង អគ្គនាយករងនៃវិទ្យាស្ថានស្តង់ដារកម្ពុជា។




### ទំនាក់ទំនងសាធារណៈ

ក្រុមហ៊ុន RMA Cambodia បានចូលរួមជាអ្នកពិភាក្សានៅក្នុងកម្មវិធី Breakfast Talk ស្តីពីទស្សនវិស័យវិស័យយានយន្តសម្រាប់ឆ្នាំ ២០២៣ ដែលរៀបចំដោយសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា និងសហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា។ តាមទស្សនៈវិស័យឯកជន លោក ងន សាំង នាយកប្រតិបត្តិក្រុមហ៊ុន RMA Cambodia និងលោក Roberto Da Silva នាយកប្រតិបត្តិក្រុមហ៊ុន HGB Group បានចែករំលែកទស្សនៈរបស់ពួកគាត់លើនិន្នាការនៃទីផ្សាររថយន្តថ្មី រថយន្តអគ្គិសនី និងការវិនិយោគដែលមានសក្តានុពលនៅក្នុង វិស័យឧស្សាហ



កម្មផលិតរថយន្ត។ លោក ឈឿន មករា ជាប្រធានគម្រោង នៃ RMA និងជាប្រធានគណៈកម្មាធិការយានយន្ត EuroCham។

## ពានរង្វាន់

វិញ្ញាបនបត្រនៃ Merit ពី World Custom Organization ដែលមានក្រុមហ៊ុនអាជីវកម្មល្អបំផុតចំនួន ១០ ដែលបានចូលរួមក្នុងការបង្កើនប្រសិទ្ធភាព នៃការសម្របសម្រួលពាណិជ្ជកម្ម ការពង្រឹងការអនុលោមតាម និងការបំពេញកាតព្វកិច្ចពន្ធ និងកាតព្វកិច្ច។


World Customs Organization
Organisation mondiale des douanes

CERTIFICATE OF MERIT

On the occasion of the International Customs Day,
the World Customs Organization awards this certificate to

RMA (CAMBODIA) Co., Ltd.

representing

Trade Facilitation Affairs in Cambodia

for rendering exceptional service to the international Customs community

Kunio Mikuriya
Secretary General

## ព្រឹត្តិការណ៍ CSR

### RMA CAMBODIA បានបរិច្ចាគជូនដល់សិស្សដែលជួបការលំបាកនៅភូមិប្រាសាទថ្មីកម្ពុជា

ក្រុមហ៊ុន អ អិម អេ ខេមបូឌា បានបរិច្ចាគកង់ និងសម្ភារៈសិក្សា ដល់សិស្សានុសិស្សដែលជួបការលំបាក នៃសាលាសៀកថ្មីកម្ពុជា ដែលជាសាលារបស់ NGO ដែលមានទីតាំងនៅក្នុងខេត្តសៀមរាប។



គណៈគ្រប់គ្រងក្រុមហ៊ុន អ អិម អេ ខេមបូឌា គ្រោងបើកម៉ូតូកង់បី Piaggio ក្នុងរាជធានីភ្នំពេញ ដើម្បីប្រមូលថវិកាបរិច្ចាគ ជូនដល់សិស្សពិការ នៃវិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី ក្នុងឱកាសទិវានៃក្តីស្រឡាញ់អន្តរជាតិ។



## ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក

សមិទ្ធិផលសំខាន់ៗក្នុងត្រីមាសទី១ នៃឆ្នាំ២០២៣ រួមមាន៖

**ភាពឈានមុខគេក្នុងទីផ្សាររបស់រថយន្តម៉ាក Ford៖**

រថយន្តម៉ាក Ford គឺជាប្រភេទរថយន្តដែលឈានមុខគេនៅលើទីផ្សារប្រទេសកម្ពុជា។ រថយន្តម៉ាក Ford Ranger ត្រូវបានជាប់ចំណាត់ថ្នាក់លេខពីរក្នុងចំណោមទីផ្សាររថយន្តដែលមិនប្រណិតក្នុងប្រទេសកម្ពុជាសម្រាប់ត្រីមាសទី១ ឆ្នាំ ២០២៣។

**គ្រឿងចក្រម៉ាក John Deere៖** ដោយយោងតាមរបាយការណ៍ផ្ទៃក្នុងរបស់ក្រុមហ៊ុន រថយន្តម៉ាក John Deere នៅជាអ្នកនាំមុខទី២ នៅក្នុងទីផ្សារត្រាក់ទ័រក្នុងប្រទេសកម្ពុជា និងរក្សាតំណែងជាអ្នកនាំមុខលើត្រាក់ទ័រធុនធំ និងម៉ាស៊ីនប្រមូលផលនៅកម្ពុជា។

**លទ្ធផលហិរញ្ញវត្ថុ៖**

ក្រុមហ៊ុន RMAC ទទួលបានចំណូលចំនួន ៦៣១,២ ប៊ីលានរៀល ក្នុងដំណាច់ត្រីមាសទី១ នៃឆ្នាំ២០២៣ ដែលមានការកើនឡើងចំនួន +៤៦,៩% ធៀបនឹងដំណាច់ត្រីមាសទី១ នៃឆ្នាំ២០២២។ សម្រាប់ដំណាច់ត្រីមាសទី១ នៃឆ្នាំ ២០២៣ ប្រាក់ចំណេញក្រោយបង់ពន្ធមានចំនួន ៦៩,៧ ប៊ីលានរៀល។

លំហូរសាច់ប្រាក់សុទ្ធដែលប្រើប្រាស់លើការវិនិយោគនូវសាច់ប្រាក់មានចំនួន ១៣.១ ប៊ីលានរៀល ក្នុងឆ្នាំ២០២៣ ដោយរាប់បញ្ចូលការសាងសង់លើបន្ទប់តាំងបង្ហាញថ្មី និងការទិញរថយន្តម៉ាកថ្មីសម្រាប់ប្រតិបត្តិការ និងឧបករណ៍ប្រតិបត្តិការបន្ថែម។

## ខ. រចនាសម្ព័ន្ធប្រាក់ចំណូល

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនដែលមានលក្ខណៈបែបចម្រុះ ដែលបានតំណាងអោយយីហោលំដាប់ពិភពលោកមួយចំនួនរួមមាន Ford, Jaguar Land Rover, Changan, After-Sales Mercedes-Be, Fuso, John Deere, JCB និង Piaggio។ ផលចំណូលរបស់ក្រុមហ៊ុនទាំងអស់ ត្រូវបានបែងចែកជាពីរប្រភេទ៖

១. ការលក់ទំនិញ៖ ចំណូលទាក់ទងនឹងការលក់យានយន្ត និងឧបករណ៍ផ្សេងៗ។

២. ចំណូលពីសេវាកម្ម៖ ចំណូលទាក់ទងនឹងសេវាជួសជុល និងថែទាំយានយន្ត និងឧបករណ៍។

តារាងខាងក្រោមបង្ហាញពីចំណូលពីរប្រភេទសម្រាប់ ត្រីមាសទី១ ឆ្នាំ២០២៣ និងរយៈពេលប្រៀបធៀបកាលពីឆ្នាំមុន។

| គិតជាពាន់រៀល | ត្រីមាសទី១ ឆ្នាំ២០២៣ | ភាគរយ | ត្រីមាសទី១ ឆ្នាំ២០២២ | ភាគរយ | ត្រីមាសទី១ ឆ្នាំ២០២១ | ភាគរយ |
|---|---|---|---|---|---|---|
| **ការលក់ទំនិញ** | ៦១៥.០៣៩.៣៣២ | ៩៧,៤% | ៤១៤.៥៨៣.២៣៤ | ៩៦,៥% | ៤៧២.០២៦.៩៣៥ | ៩៨,០% |
| **ចំណូលនៃសេវាកម្ម** | ១៦.១៤៨.៩៧៤ | ២,៦% | ១៥.០៨៥.៦៨៣ | ៣,៥% | ៩.៦២៨.០៧៣ | ២,០% |
| **សរុប** | ៦៣១.១៨៨.៣០៦ | ១០០,០% | ៤២៩.៦៦៨.៩១៧ | ១០០,០% | ៤៨១.៦៥៥.០០៨ | ១០០,០% |

## ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ

សូមយោងទៅកាន់ឧបសម្ព័ន្ធស្តីពីព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នប្រចាំត្រីមាស គិតត្រឹម

ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

## ផ្នែកទី៤. ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ១. ការវិភាគចំណូល

ចំណូលសរុប មានចំនួន ៦៣១,២ ប៊ីលានរៀល កើនឡើងចំនួន +២០១,៥ប៊ីលានរៀល ឬ +៤៦,៩% ភាគរយ នៅក្នុងត្រីមាសទី១ ឆ្នាំ២០២៣ បើធៀបនឹងត្រីមាសក្នុង ឆ្នាំ២០២២។

#### ២. ផ្នែកនៃចំណូល

ប្រាក់ចំណូលត្រូវបានបែងចែកចេញពីផ្នែកជាច្រើនរបស់ក្រុមហ៊ុន ដែល Ford គឺជាផ្នែកលក់ភាគច្រើន។ ផ្នែកផ្សេងទៀតនៃវិស័យកសិកម្ម រថយន្ត Jaguar Land Rover, គ្រឿងបរិក្ខាឧស្សាហកម្ម និង Piaggio បានកើនឡើងពេញមួយឆ្នាំនេះដែរ។

#### ៣. ការវិភាគអំពីប្រាក់ចំណេញមុនបង់ពន្ធ (PBT)

| គិតជាពាន់រៀល | ត្រីមាសទី១ ឆ្នាំ២០២៣ | ត្រីមាសទី១ ឆ្នាំ២០២២ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ចំណូលសរុប | ៦៣១.១៨៨.៣០៦ | ៤២៩.៦៦៨.៩១៧ | ២០១.៥១៩.៣៨៩ | ៤៦,៩% |
| ចំណេញដុល | ១១៥.៦២៩.៤០៦ | ៧៥.៤៧៦.៣៥៦ | ៤០.១៥៣.០៥០ | ៥៣,២% |
| គម្លាតចំណេញដុល | ១៨,៣% | ១៧,៦% | | |
| ចំណាយ | ២១.៤៧៥.០៩៨ | ១៩.០៩៦.០៣៥ | ២.៣៧៩.០៦៣ | ១២,៥% |
| ចំណាយហិរញ្ញវត្ថុ | ៥.៤៤០.៧៩៩ | ១.៩៩៧.៥៧៨ | ៣.៤៤៣.២២១ | ១៧២,៤% |
| ប្រាក់ចំណេញមុនបង់ពន្ធ | ៨៨.៧១៣.៥០៩ | ៥៤.៣៨២.៧៤៣ | ៣៤.៣៣០.៧៦៦ | ៦៣,១% |
| គម្លាត | ១៤,១% | ១២,៧% | | |

#### ៤. ការវិភាគអំពីប្រាក់ចំណេញក្រោយបង់ពន្ធ (PAT)

| គិតជាពាន់រៀល | ត្រីមាសទី១ ឆ្នាំ ២០២៣ | ត្រីមាសទី១ ឆ្នាំ ២០២២ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ៨៨.៧១៣.៥០៩ | ៥៤.៣៨២.៧៤៣ | ៣៤.៣៣០.៧៦៦ | ៦៣,១% |
| ចំណាយពន្ធ | ១៩.០៥៧.៥៨៦ | ៦.៣១១.៣៧១ | ១២.៧៤៦.២១៥ | ២០២,០% |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | ៦៩.៦៥៥.៩២៣ | ៤៨.០៧១.៣៧២ | ២១.៥៨៤.៥៥១ | ៤៤,៩% |
| គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ | ១១,០% | ១១,២% | | |

### ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ

#### ១. ការវិភាគអំពីតម្រូវការ និង ការផ្គត់ផ្គង់

អតិថិជនបានបង្ហាញពីចំណាប់អារម្មណ៍របស់ពួកគេក្នុងការទិញផលិតផលសំខាន់ៗរបស់យើងមានដូច ជា Ford, John Deere និង Jaguar Land Rover ។ តម្រូវការបានរក្សាឲ្យស្ថិតក្នុងកម្រិតខ្ពស់សម្រាប់ ត្រីមាសទី៤ ឆ្នាំ២០២២ ជាមួយនឹងចំនួនទៀងទាត់នៃកិច្ចសន្យារបស់អតិថិជនដែលត្រូវបានចុះបញ្ជីនៅចុះត្រីមាស។

ទោះបីជាកង្វះសារពើភ័ណ្ឌបានធូរស្រាលលើម៉ូដែលមួយចំនួនក៏ដោយ ក៏នៅតែមានការខ្វះខាតជាសាកលនៃសមាសធាតុសំខាន់ៗមួយចំនួនដូចជា មីក្រូឈីប(micro-chip) ដែលជះឥទ្ធិពលអវិជ្ជមានដល់ឧស្សាហកម្មរថយន្ត ហើយជាក់ស្តែងឧស្សាហកម្មរថយន្តត្រូវរងផលប៉ះពាល់ ។ ផលិតផល ឬម៉ូដែលមួយចំនួន អាស្រ័យលើប្រភពដើមនៃផលិតផល និងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់នៃ កូវីដ-១៩ មានការប្រឈមកាន់តែខ្លាំងចំពោះធនធាន។

RMAC កំពុងតាមដានយ៉ាងជិតដល់នូវការនាំចូល និងស្តុកទុកនូវធនធាននៃផលិតផលសម្រាប់ផ្នែកនីមួយៗ ប៉ុន្តែអាចប្រឈមនឹងការខ្វះខាតផលិតផលមួយចំនួននៅក្នុងត្រីមាសបន្ទាប់។

### ២. ការវិភាគអំពីការប្រែប្រួលនូវតម្លៃវត្ថុធាតុដើម

មិនមានការប្រែប្រួលសំខាន់លើតម្លៃនៃវត្ថុធាតុដើមឡើយ។

### ៣. ការវិភាគអំពីពន្ធដារ

មិនមានការប្រែប្រួលលើលិខិតបទដ្ឋានគតិយុត្តិផ្នែកពន្ធដារក្នុងប្រទេសកម្ពុជាណាមួយ ដែលនាំអោយមានផលប៉ះពាល់សំខាន់ណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

### ៤. ការវិភាគអំពីទំនិញលើកលែង និងទំនិញពិសេស

មិនមានទំនិញលើកលែង និងទំនិញពិសេសក្នុងអំឡុងពេលនេះឡើយ។

## គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល

ចំណូលសម្រាប់ត្រីមាសទី១ ឆ្នាំ២០២៣ ប្រៀបធៀបរយៈពេលនេះជាមួយនឹងឆ្នាំ ២០២២ ត្រូវបានបង្ហាញក្នុងឯកសារនេះ និងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេប។

## ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ

ការប្រែប្រួលអត្រាប្តូរប្រាក់ មិនមានការប៉ះពាល់ចំបងណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ ដោយហេតុថាអាជីវកម្មមួយចំនួនធំរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់រៀល/ប្រាក់ដុល្លារអាមេរិក ភ្ជាប់ជាមួយនឹងការបញ្ជាទិញនូវផលិតផលនាំចូលតិចតួចប៉ុណ្ណោះដែលធ្វើឡើងជារូបិយបណ្ណបរទេស។ ក្រុមហ៊ុន មិនបានទទួលរងផលប៉ះពាល់ដោយតម្លៃទំនិញ ដោយសារក្រុមហ៊ុនមិនបានធ្វើការដោះដូរទំនិញឡើយ។ អត្រាការប្រាក់ មានការប្រែប្រួលបន្តិចបន្តួចតែប៉ុណ្ណោះក្នុងអំឡុងពេលនេះ។

## ង. ផលប៉ះពាល់នៃអតិផរណា

មិនមានផលប៉ះពាល់ចំបងណាមួយនៃអតិផរណា ដែលបានប៉ះពាល់ដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

មិនមានផលប៉ះពាល់ចំបងណាមួយដែលបណ្តាលមកពីការប្រែប្រួលនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលឡើយ។ ចាប់តាំងពីស្ថានភាពនៃជម្ងឺរាតត្បាតនៃកូវីដ-១៩ មានការប្រសើរឡើង យើងសម្គាល់ឃើញថាវិធានការនៃការរឹតបន្តឹងរបស់រដ្ឋាភិបាលត្រូវបានកាត់បន្ថយ។ ចំណែកឯស្ថានភាពសេដ្ឋកិច្ចក៏មានលក្ខណៈល្អប្រសើរឡើយវិញ ជាពិសេសទៅលើវិស័យទេសចរណ៍។

## ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ

មិនមានព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសនេះទេ។

ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ

កាលបរិច្ឆេទៈ ៣១ ឧសភា ២០២៣

| | |
|---|---|
| បានឯកភាព និង អនុម័ត | បានឯកភាព និង អនុម័ត |
| ឈ្មោះ Kevin Whitcraft | ឈ្មោះ ងន សាំង |
| តួនាទីៈ ប្រធានក្រុមប្រឹក្សាភិបាល | តួនាទីៈ នាយកប្រតិបត្តិ |

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន អ រិម អេ (ខេមបូឌា) ម.ក RMA (CAMBODIA) PLC. KINGDOM OF CAMBODIA

